**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០២៣-០០៥ ប្រ.ក

# ប្រកាស
# ស្តីពី
# ប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៩/៦៤២ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ ស្តីពី ការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា ជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជានិងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៩ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពី ការកែសម្រួលប្រការ៣ ប្រការ ៤ ប្រការ ៥ ប្រការ ១២ និងប្រការ ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងតាមការចាំបាច់របស់ធនាគារជាតិនៃកម្ពុជា

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អត្រាប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើនិងប្រាក់កម្ចីជារូបិយវត្ថុជាតិ និងរូបិយប័ណ្ណ សំដៅអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា តទៅនេះហៅថា "គ្រឹះស្ថាន"។

**ប្រការ ៣.-**

គ្រឹះស្ថានត្រូវតម្កល់ប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើនិងប្រាក់កម្ចីជាមធ្យមជាប្រចាំថ្ងៃនៅធនាគារជាតិនៃកម្ពុជា តាមកាលបរិច្ឆេទនិងអត្រា ដូចខាងក្រោម៖

- ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណត្រូវមានកម្រិត ៩% (ប្រាំបួនភាគរយ)
- ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ តទៅ ប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណត្រូវមានកម្រិត ១២,៥% (ដប់ពីរក្បៀសប្រាំភាគរយ)។

ចំណែកឯប្រាក់បម្រុងកាតព្វកិច្ចជារូបិយវត្ថុជាតិ គ្រឹះស្ថានត្រូវរក្សាអត្រានៅកម្រិត ៧% (ប្រាំពីរភាគរយ) ដដែល។

**ប្រការ ៤.-**

ប្រកាសលេខ ធ៧-០២០-២៣០ ប្រ.ក ចុះថ្ងៃពុធ ១០រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ស្តីពី ប្រាក់បម្រុងកាតព្វកិច្ច នៃប្រាក់បញ្ញើនិងប្រាក់កម្ចីរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-**

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបច្ចេកទេស អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្ថិតក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ៣រោច ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមករា ឆ្នាំ ២០២៣

**ទេសាភិបាល**

**ជា_ចាន់តូ**

**កន្លែងទទួល៖**

- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន៖**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"